# សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ**

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង

សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

០៧ មិនា ២០១៤

- **សូមគោរព លោកស្រី អ៊ីតា ហ្សុគិមិ តំណាងសមាគម អាសាក់(ASAC)!**
- **សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយខ្លាំងណាស់ដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ទៅលើគម្រោងសាងសង់និងជួសជុលសាលាបឋមសិក្សានិង អនុវិទ្យាល័យក្នុងខេត្តកំពត។

សមាគមជំនួយសាលារៀននៅកម្ពុជា(ASAC) បាននិងកំពុងពង្រីកសកម្មភាពផ្តល់ជំនួយទៅលើការសាងសង់សាលានិងការអប់រំអក្ខរកម្មនៅកម្ពុជាអស់រយៈពេលជាង២០ឆ្នាំមកហើយតាំងពីឆ្នាំ១៩៩៤មក ជាមួយនឹងការសហការយ៉ាងជិតស្និទ្ធិពីរដ្ឋាភិបាលជប៉ុន។ ជាពិសេស ទាក់ទងទៅនឹងការសាងសង់សាលានេះដែរ រហូតមកដល់ពេលនេះ មានសាលាបឋមសិក្សា និង អនុវិទ្យាល័យជាង១៣០ខ្នងហើយដែលត្រូវបានសាងសង់ក្នុងខេត្តកំពត។

នៅក្នុងយុទ្ធសាស្រ្តចតុកោណដែលជាយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ គឺរាជរដ្ឋាភិបាលកម្ពុជាក៏បានផ្តោតចំណុចសំខាន់ទៅលើការបណ្តុះបណ្តាលធនធានមនុស្សផងដែរ។ រដ្ឋាភិបាលជប៉ុនក៏បាននិងកំពុងបន្តផ្តល់ជំនួយទៅលើផ្នែកទន់ ដូចជា ការបណ្តុះបណ្តាលគ្រូបង្រៀនផ្នែកគណិតវិទ្យានិងវិទ្យាសាស្រ្ត ទន្ទឹមនឹងការសហការទៅលើផ្នែករឹង មានដូចជា ការសាងសង់សាលាបឋមសិក្សានិង អនុវិទ្យាល័យ ការសាងសង់អគារពិសោធន៍វិទ្យាសាស្រ្តនៅក្នុងសាលាបណ្តុះបណ្តាលគ្រូបង្រៀនជាដើម។

ទាក់ទងនឹងសាលាបឋមសិក្សាអម្ពរវន្តឃោធារ៉ាម និង អនុវិទ្យាល័យទួលធ្វឹកនៃខេត្តកំពតដែលនឹងត្រូវសាងសង់ក្នុងពេលខាងមុខនេះ ខ្ញុំបានលឺថា សាលាកំពុងតែខ្វះអគារដែលគ្មានជញ្ជាំងរបស់វត្តដែលស្ថិតនៅម្ខាងទៀតនៃផ្លូវ ដែលធ្វើឲ្យសិស្សានុសិស្សមានការលំបាកក្នុងការដើរឆ្លងទៅសិក្សា ហើយម៉្យាងវិញទៀតក្រោមហេតុផលថាគ្មានបន្ទប់សិក្សាគ្រប់គ្រាន់ធ្វើឱ្យការសិក្សាក្នុង១សប្តាហ៍ដែលតម្រូវអោយសិស្សសិក្សាលើសពី៣២ម៉ោង តែសិក្សាបានតែ៣០ម៉ោងប៉ុណ្ណោះ។

តាមរយៈគម្រោងលើកនេះ អគារ២ខ្នងស្មើនិង៨បន្ទប់នឹងត្រូវបានសាងសង់ និង អគារ១ខ្នងស្មើនិង៣បន្ទប់ នឹងត្រូវបានជួសជុល ដូច្នេះទោះបីជាពេលមានភ្លៀងឬមានខ្យល់ខ្លាំងយ៉ាងណាក៏ដោយ ក៏សិស្សនៅតែអាចទទួលបានការសិក្សាដោយគ្មានការព្រួយបារម្ភ ហើយខ្ញុំសង្ឃឹមថា សិស្សានុសិស្សជាង៥០០នាក់ដែលសិក្សានៅសាលាបឋមសិក្សានិងអនុវិទ្យាល័យនេះនឹងអាចទទួលបានការសិក្សាលើសពី៣២ម៉ោងក្នុង១សប្តាហ៍ ហើយបរិស្ថានសិក្សានឹងត្រូវបានធ្វើឲ្យប្រសើរឡើងមួយកំរិតធំផងដែរ។

ជាចុងបញ្ចប់ ដោយជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន គឺជាជំនួយដែលត្រូវផ្តល់ជូនដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជននៅកម្រិតមូលដ្ឋាននោះ ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះនឹងផ្តល់អត្ថប្រយោជន៍ផ្ទាល់ដល់ប្រជាជននៅក្នុងតំបន់គោលដៅ ព្រមទាំងរួមចំណែកជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងជប៉ុន និង កម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!